ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

របាយការណ៍
ស្តីពី
លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិការប្រចាំត្រីមាសទី៤ ឆ្នាំ២០២២
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សេចក្តីផ្តើម

ឆ្នាំ២០២២ គឺជាឆ្នាំទី៧ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព"។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកា និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន២៥ រាជធានី ខេត្ត។

I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ បានប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ នៅក្នុងច្បាប់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងឥណទានចំណាយថវិកាឆ្នាំ២០២២ សរុបមានចំនួន២៥៨ ៣២៧លានរៀល ក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល** ៖ បានគ្រោងឥណទានចំណាយថវិកាសរុបចំនួន ១៦២ ៤២១ លានរៀល រួមមាន ៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន១៥៣ ៤២១លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ៩ ០០០លានរៀល

(ខ) **មន្ទីរាជធានី ខេត្ត** ៖បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន៩៥ ៩០៦លានរៀល

II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នៅក្នុងត្រីមាសទី៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តចំណាយតាមអាណត្តិបើកប្រាក់សរុបចំនួន៧៥ ៣៨៣ លានរៀល ស្មើនឹង៩៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ក្នុងនោះ រដ្ឋបាលកណ្តាលអនុវត្តបានចំនួន៥២ ១២៦,៦លានរៀល ស្មើនឹង៩៩,៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៦,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ រីឯមន្ទីរាជធានី ខេត្ត អនុវត្តបានចំនួន២៣ ២៥៦,៤លានរៀល ស្មើនឹង៩៧,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៩៣,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(ក) រដ្ឋបាលកណ្តាល ៖

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់

របស់រដ្ឋបាលកណ្តាល (២១អង្គភាពថវិកា) សម្រេចបានចំនួន៥២ ១២៦,៦លានរៀល ដោយក្នុងនោះ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន១០ ៣៨២,៤លានរៀល ស្មើនឹង១០០,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ១០៤,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សោភកម្ម (ជំពូក៦១) អនុវត្តបានចំនួន១៦ ៩១៧,៨លានរៀល ស្មើនឹង ៨៧,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៥,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្តបានចំនួន២១ ១៨២,៨លានរៀល ស្មើនឹង១០០,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ៦៦,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៣ ៥៦១,៧លានរៀល ស្មើនឹង ៩៩,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៩១,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង)ពន្ធនិង អាករ(ជំពូក៦៣) អនុវត្តបានចំនួន៨១,៩លានរៀល ស្មើនឹង៧៧,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ៩១,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

ម៉្យាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថា ទឹកប្រាក់សរុបចំនួន៥២ ១២៦,៦លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់ ៖

(១) បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងកសិធុរកិច្ច(កម្មវិធីទី១) ចំនួន៩ ១២៣,៦លានរៀល ស្មើនឹង ១០២,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២។ ការអនុវត្តលើសច្បាប់គឺដោយសារថវិកាបន្ថែមជំពូក២១ ចំនួន ៣ ០៨០ លានរៀល។

(២) ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ (កម្មវិធីទី២) ចំនួន៤ ៣៩៥,២លានរៀល ស្មើនឹង៩៣,៧% ធៀបនឹង ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៣) គ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន៦ ២៨៣,៣ លានរៀល ស្មើនឹង១០៨,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៤) គ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ (កម្មវិធីទី៤) ចំនួន៤ ៩០០លានរៀល ស្មើនឹង៩២,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

(៥) បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស(កម្មវិធីទី៥) ចំនួន២៧ ៤២៤,៥លានរៀលស្មើ នឹង៩៨,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២។

(ខ) មន្ទីរាជធានី ខេត្ត ៖

យោងតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥រាជធានី ខេត្តបានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ២៣ ២៥៦,៤ លានរៀល គឺអនុវត្តបានខ្ពស់ជាងឆ្នាំ២០២១ ក្នុងរយៈពេលដូចគ្នាប្រមាណជា៤% ក្នុងនោះចំណាយលើ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន១ ៧០២,៧លានរៀល ស្មើនឹង៩៧,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ៩៧,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(ខ)សោភកម្ម (ជំពូក៦១)អនុវត្តបានចំនួន៦ ៤៨៦,៩លានរៀលស្មើនឹង៩៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(គ)បន្ទុកបុគ្គលិក(ជំពូក៦៤) អនុវត្តបានចំនួន១៤ ៤៣៨,៥លានរៀល ស្មើនឹង៩៦,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៩៤,៣% ធៀបនឹង កម្មវិធីដែលបានដាក់ចេញ (ឃ)អត្ថប្រយោជន៍សង្គម (ជំពូក៦២) អនុវត្តបានចំនួន៦៥១,៩ លានរៀល ស្មើនឹង៩៩,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១០៦,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) អនុវត្តបានចំនួន១៦,៨លានរៀល ស្មើនឹង៨៥,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៣១,៦% ធៀបនឹងកម្មវិធី ដែលបានដាក់ចេញ។

ម៉្យាងទៀត ដោយពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុប ចំនួន២៣ ២៥៦,៤លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ដូចខាងក្រោម៖

ឯកតា: រៀល

មន្ទីរ/រាជធានី ខេត្ត	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២	កម្មវិធី ត្រីមាសទី៤	ការអនុវត្ត ត្រីមាសទី៤	%អនុ.ត្រីម ត្រី.ទី៤ធៀបច្ប. ២០២២	%ធៀបកម្មវិធី ត្រីមាសទី៤
បន្ទាយមានជ័យ	3 820 600 000	1 482 845 000	1 356 436 399	94.3%	91.5%
បាត់ដំបង	6 327 800 000	1 415 054 000	1 244 990 322	97.2%	87.9%
កំពង់ចាម	4 035 000 000	902 707 000	937 132 902	97.5%	103.8%
កំពង់ឆ្នាំង	3 862 500 000	816 527 000	959 881 400	101.1%	117.6%
កំពង់ស្ពឺ	4 513 600 000	1 274 292 000	1 006 226 520	98.9%	78.9%
កំពង់ធំ	5 498 500 000	2 302 869 000	1 512 551 727	96.5%	65.7%
កំពត	3 933 400 000	969 830 000	838 725 190	103.7%	86.5%
កណ្តាល	6 123 700 000	1 078 059 000	1 242 330 834	97.9%	115.2%
កោះកុង	2 432 100 000	611 886 000	666 653 464	99.6%	172.9%
ក្រចេះ	3 943 600 000	624 839 000	620 368 763	98.0%	99.3%
មណ្ឌលគិរី	2 774 100 000	979 881 000	912 682 700	93.2%	93.1%
រាជធានីភ្នំពេញ	3 843 300 000	1 377 449 000	1 238 353 710	89.2%	89.9%
ព្រះវិហារ	2 713 100 000	959 584 000	860 605 000	97.5%	89.7%
ព្រៃវែង	4 357 400 000	1 602 857 000	1 746 038 760	98.6%	108.9%
ពោធិ៍សាត់	3 822 100 000	870 348 000	791 339 652	97.5%	90.9%
រតនគិរី	3 147 100 000	513 702 000	443 758 900	95.5%	86.4%
សៀមរាប	5 700 600 000	1 377 739 000	1 736 361 100	95.1%	126.0%
ព្រះសីហនុ	2 833 700 000	558 995 000	471 512 160	98.3%	84.4%
ស្ទឹងត្រែង	3 315 900 000	689 352 000	374 258 590	96.3%	54.3%
ស្វាយរៀង	2 998 400 000	554 753 000	547 549 650	96.6%	98,7%
តាកែវ	5 407 600 000	1 164 894 000	1 128 992 948	103.2%	96.9%
ឧត្តរមានជ័យ	2 994 800 000	706 147 000	624 291 800	96.8%	88.4%
កែប	1 646 100 000	678 385 000	706 821 940	91.0%	104.2%
ប៉ៃលិន	2 161 100 000	429 485 000	344 611 400	97.1%	80.2%
ត្បូងឃ្មុំ	3 699 900 000	1 014 737 000	943 868 372	93.3%	93.0%

III-បញ្ហាប្រឈម

យោងតាមការអធិប្បាយខាងលើ ការអនុវត្តចំណាយចរន្តរបស់រដ្ឋបាលកណ្តាលលើការចំណាយផ្នែកសេវាកម្ម (ជំពូក៦១) អនុវត្តបានទាបគិតមកត្រឹមត្រីមាសទី៤ គឺដោយសារអង្គភាពថវិកាមួយចំនួនត្រូវកែសម្រួលផែនការចំណាយពីទូទាត់ត្រង់ ទៅជាចំណាយតាមនីតិវិធីលទ្ធកម្ម ស្របទៅតាមគោលការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ករណីនេះ តម្រូវឱ្យកែប្រែផែនការលទ្ធកម្មឡើងវិញចំនួនពីរលើក គួបផ្សំនឹងការទទួលបានធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយឺត ពោលគឺមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់បន្តអនុវត្តនីតិវិធីលទ្ធកម្មបាន នូវទឹកប្រាក់ចំនួន៦១០លានរៀល សម្រាប់ការងារជួសជុលកែលម្អអគារនិងប្រព័ន្ធលូរបស់អង្គភាពក្រោមឱវាទក្រសួង។

IV-ទិសដៅអនុវត្តបន្ត

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាករបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន៥៩ ៨០៩ ០៩៣ ០០០រៀល ក្នុងនោះរួមមាន ៖

ឯកតា: រៀល

ចំណាត់ថ្នាក់សេដ្ឋកិច្ច	រដ្ឋបាលកណ្តាល	មន្ទីររាជធានី ខេត្ត
ជំពូក ៦០ (ការទិញ)	4 600 000 000	2 980 010 000
ជំពូក ៦១ (សេវាកម្ម)	6 100 000 000	3 873 487 000
ជំពូក ៦៤ (បន្ទុកបុគ្គលិក)	20 000 000 000	14 666 321 000
ជំពូក៦២(អត្ថប្រយោជន៍សង្គម)		1 505 275 000
ជំពូក ៦៥ (ឧបត្ថម្ភធន)	6 084 000 000	
ជំពូក ៦៣ (ពន្ធនិងអាករ)		
សរុប	**36 784 000 000**	**23 025 093 000**

V-សេចក្តីសន្និដ្ឋាន

ឆ្លងតាមការពិនិត្យវាយតម្លៃការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី៤ របស់អង្គភាពថវិកានៃរដ្ឋបាលកណ្តាល ជារួមសម្រេចបាន៩៩,៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៦,២% នៃកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះបានមកដោយសារការចំណាយលើការទិញ ចំណាយឧបត្ថម្ភធន អនុវត្តបានល្អប្រសើរ។ ទន្ទឹមនេះចំណាយបន្ទុកបុគ្គលិកនិងចំណាយមូលធនអនុវត្តលើសច្បាប់ហិរញ្ញវត្ថុ ដោយសារការបន្ថែមឥណទានថវិកាជំពូក៦៤ សម្រាប់ការទូទាត់ប្រាក់រង្វាន់ចំនួន១ ១៦៧,៧លានរៀល និងការបន្ថែមឥណទានថវិកាជំពូក២១ សម្រាប់ការងារសាងសង់និងហេដ្ឋារចនាសម្ព័ន្ធ ចំនួន៣ ១០០លានរៀល។ ដោយឡែក ចំណាយសេវាកម្ម(ជំពូក៦១) អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុប្រមាណជា១៣% លទ្ធផលនេះបណ្តាលមកពីការខកខានមិនបានបន្តអនុវត្តនីតិវិធីលទ្ធកម្ម សម្រាប់ការងារជួសជុលកែលម្អអគារនិងប្រព័ន្ធលូរបស់អង្គភាពក្រោមឱវាទ នូវទឹកប្រាក់ចំនួន៦១០លានរៀល។ ម្យ៉ាងទៀត ចំណាយអត្ថប្រយោជន៍សង្គម(ជំពូក៦២) មិនបានអនុវត្តដោយសារក្រសួងមិនបានរៀបចំប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការប្រចាំឆ្នាំ២០២២ ចំនួន៦០លានរៀល ។

ចំពោះការអនុវត្តចំណាយថវិការបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមសម្រេចបានល្អក្នុងកម្រិត ៩៧,២% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៩៧,២%នៃកម្មវិធីដែលបានដាក់ចេញ។

សរុបសេចក្តីមក ការអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមនៅតែទទួលបានលទ្ធផលល្អប្រសើរ ទោះបីជាមានការយឺតយ៉ាវ ឬខកខានលើការអនុវត្តចំណាយតាមនីតិវិធីលទ្ធកម្មមួយចំនួនក្តី។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តចេញលិខិតណែនាំបន្ថែមពាក់ព័ន្ធនឹងការលើកគម្រោងស្នើសុំធានាចំណាយមុខសញ្ញាដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីលទ្ធកម្ម សាធារណៈ ដើម្បីកែលម្អការអនុវត្តចំណាយថវិកាឱ្យបានកាន់តែប្រសើរថែមទៀតនៅក្នុងឆ្នាំ២០២៣ នេះ ។

ថ្ងៃពុធ ១០ កើត ខែ ដល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២៣
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋលេខាធិការ

ឆេង ពឺម ស្ទុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

របាយការណ៍
ស្តីពី
លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ បានប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២២ សរុបមានចំនួន៣៧ ១៤៤,៨លានរៀល ក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល** ៖ បានគ្រោងចំណូលសរុបចំនួន៣៧ ១៤៣,៤លានរៀល ចំណូលនេះរួមមាន៖

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២០ ៩៩២លានរៀល ស្មើនឹង១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន១២ ៨៣១,៤លានរៀល ស្មើនឹង១១៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ (៣)ផលពីការជាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៣ ៣២០លានរៀល ស្មើនឹង១០១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១។

(ខ) **មន្ទីរាជធានី ខេត្ត**៖ បានគ្រោងចំណូលសរុបចំនួន១,៤លានរៀល ស្មើនឹង ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការលក់ជួលទ្រព្យសម្បត្តិ និងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ នៅក្នុងត្រីមាសទី៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូល សរុបមានចំនួន១២ ៤២០,៩លានរៀល ស្មើនឹង១១៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៤៧,៣%ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល**៖ អនុវត្តប្រមូលចំណូល សរុបមានចំនួន១២ ៤២០,៩លានរៀល ស្មើនឹង១១៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៤៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន៤ ៣៥៧,៦លានរៀល ស្មើនឹង៩២,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៣,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន៣ ៩៧៦,៥ លានរៀល ស្មើនឹង១៣៧,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១៥៣,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣)ផលពីការជាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៤៥៤,៨លានរៀល ស្មើនឹង៦៥,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧២,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៤)ផលហិរញ្ញវត្ថុ មានចំនួន១៣១លានរៀល ជាចំណូលបានមកពីការបង់សំណែសចំណាយប្រាក់បៀវត្ស (៤)ផលផ្សេងៗនិងផលពិសេស មានចំនួន៣ ៥០១លានរៀល

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax: (855) 23-217 320

ក្នុងនោះ:(១) ចំណូលពីការលក់ផ្តាច់ចំណែកដីនៃសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនវើលដ៏ទ្រីស្តារ អិនធើថេនមេន (ខេមបូឌា) អិលធើឌី(ស្រុកឈូក ខេត្តកំពត)ចំនួន៣ ៤៦៣,២លានរៀល (២) ចំណូលពីការបង់ថវិកាបដិភាគដើម្បីបិទបញ្ចប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចជំហានទី២ (LASED II-MAFF) ចំនួន៣៧,៨លានរៀល។

(ខ) មន្ទីរាជធានី ខេត្ត ៖

នៅក្នុងត្រីមាសទី៤នេះមន្ទីរមិនទាន់បានអនុវត្តចំណូលពីថ្លៃឈ្នួលដីនៅឡើយ។

ជារួមការអនុវត្តចំណូល របស់រដ្ឋបាលកណ្តាលសម្រេចបានល្អប្រសើរគឺលើសកម្មវិធីដែលបានដាក់ចេញ ម៉្យាងទៀតដោយពិនិត្យទៅតាមប្រភេទចំណូលនីមួយៗឃើញថាមានភាពលូនធៀបនឹងកម្មវិធីដែលបានដាក់ចេញដូចជា៖

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបានល្អគឺ៨៣,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ករណីនេះបណ្តាលមកពីចំណូលផលពីព្រៃឈើអនុវត្តបាន៨៤,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៤,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញនិងចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបាន៩៩,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១០០,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា អនុវត្តបានខ្ពស់គឺ១៥៣,២ % ធៀបនឹងកម្មវិធីដែលបានដាក់ចេញ លទ្ធផលដែលសម្រេចបាននេះគឺដោយសារចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ អនុវត្តបាន៨៤,៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៨៩,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ដូចជាការជួលដីទំនេរ និងដីមានអគារអនុវត្តបាន៩៥,៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ១៦២,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកចំណូលផលពីការគ្រប់គ្រងរដ្ឋបាលដែលបានពីការត្រួតពិនិត្យអនាម័យសត្វនិងការត្រួតពិនិត្យគុណភាពផលិតផល អនុវត្តបាន១២០,៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ២១៨,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ម៉្យាងទៀតចំណូលពីការត្រួតពិនិត្យគុណភាពផលិតផលនិងការគោរពបទដ្ឋាន អនុវត្តបានខ្ពស់គឺ១៩២,៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង២៥២,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ទន្ទឹមនេះចំណូលពីការជួលដីទំនេរអនុវត្តបានល្អប្រសើរគឺ១០៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង១១៤,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកចំណូលពីការលក់ផលិតផលកសិកម្មមិនបានអនុវត្តនៅក្នុងត្រីមាសទី៤នេះ។

(៣)ចំណូលពីការជាកពិន័យនិងដាក់ទណ្ឌកម្មអនុវត្តបានបង្គួរគឺ៧២,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះបានមកដោយសារការជាកពិន័យលើផលិតផលសាច់សត្វ និងការដឹកជញ្ជូនសត្វ របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ អនុវត្តបាន២៥៣,៣%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ឬស្មើនឹង១០០% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន៣៦៩,៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៧៦,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបានបង្គួរគឺ៧៧,៧% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង ៨៤,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យតាមសាលក្រមតុលាការអនុវត្តបាន២០៥,៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ឬស្មើនឹង៦៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកការពិន័យលើបទល្មើសដីធ្លាំកសិកម្មមិនបានអនុវត្តនៅក្នុងអំឡុងពេលនេះ។

III-ទិសដៅអនុវត្តបន្ត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន៩ ៣៣២ ,៩លានរៀល។ កិច្ចការចាំបាច់មួយទៀតដែលក្រសួងត្រូវបន្តអនុវត្តគឺកិច្ចសហការរៀបចំឯកសារកែសម្រួលកម្រងសេវាសាធារណៈ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

IV-សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី៤ របស់រដ្ឋបាលកណ្តាលជារួមសម្រេចបានលទ្ធផលល្អប្រសើរ ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ទាំងផ្នែកចំណូលពីសេវាសាធារណៈ ការជួលដីធ្លី និងដីសម្បទានសេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី រហូតមកទល់ពេលនេះចំណូលពីការលក់ផលិតផលកសិកម្ម(លក់គោ)នៅភ្នំតាម៉ៅមិនទាន់បានអនុវត្តនៅឡើយ។

ដូច្នេះ ដើម្បីអនុវត្តប្រមូលចំណូលឱ្យបានតាមផែនការឆ្នាំ២០២៣ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលចូលថវិការដ្ឋឱ្យបានទាន់ពេលវេលា គួបផ្សំនឹងការប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ថ្ងៃអង្គារ ១០កើតខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២៣

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋលេខាធិការ

ឆេង គីមស៊ិន